**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋាន
## របស់មន្ត្រីនគរបាលជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/ ១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៨៩ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលប្រព័ន្ធបៀវត្សរ៍នគរបាលជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច :

**មាត្រា ១ :** អនុក្រឹត្យនេះមានគោលដៅកែសម្រួលប្រាក់បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ ។

**មាត្រា ២ :** ប្រាក់បៀវត្សរ៍មូលដ្ឋានរបស់មន្ត្រីនគរបាលជាតិ គឺត្រូវបានបែងចែកតាមលំដាប់ថ្នាក់ឋានន្តរស័ក្តិ និងត្រូវបានផ្តល់ទៅតាមសន្ទស្សន៍ដូចមានកំណត់ក្នុងតារាងខាងក្រោម :

| ល.រ | ឋានន្តរស័ក្តិ | តំលៃឥសន្ទស្សន៍ប្រាក់បៀវត្សរ៍ |
|---|---|---|
| ១ | នាយឧត្តមសេនីយ៍ | ៥៥០ |
| ២ | ឧត្តមសេនីយ៍ឯក | ៥៣០ |
| ៣ | ឧត្តមសេនីយ៍ទោ | ៥១០ |
| ៤ | ឧត្តមសេនីយ៍ត្រី | ៤៥០ |
| ៥ | វរសេនីយ៍ឯក | ៤៤២ |
| ៦ | វរសេនីយ៍ទោ | ៤១០ |
| ៧ | វរសេនីយ៍ត្រី | ៣៧០ |
| ៨ | អនុសេនីយ៍ឯក | ៣៣៦ |
| ៩ | អនុសេនីយ៍ទោ | ៣០៨ |
| ១០ | អនុសេនីយ៍ត្រី | ២៨០ |
| ១១ | នាយចំណង់ | ២៤៥ |
| ១២ | ព្រឹន្ទបាលឯក | ២៣៣ |
| ១៣ | ព្រឹន្ទបាលទោ | ១៩៣ |
| ១៤ | ពលបាលឯក | ១៧១ |
| ១៥ | ពលបាលទោ | ១៦៣ |
| ១៦ | ពលបាលត្រី | ១៥៥ |

**មាត្រា៣ :** តំលៃឯកតាសន្ទស្សន៍សម្រាប់អនុវត្ត និងការកែប្រែត្រូវអនុវត្តតាមអនុក្រឹត្យ ស្តីពីតម្លៃឯកតានៃសន្ទស្សន៍របស់មន្ត្រីរាជការស៊ីវិល ។

**មាត្រា ៤ :** មន្ត្រីនគរបាលជាតិដែលមានសិទ្ធិទទួលប្រាក់បៀវត្សរ៍ក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ត្រូវស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម :

១- កំពុងបំពេញការងារក្នុងក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ។

២- កំពុងផ្លាស់ប្តូរកន្លែងធ្វើការ និងកំពុងធ្វើដំណើរទៅកាន់មុខតំណែងនៅក្នុង ឬក្រៅប្រទេស ។

៣- កំពុងបំពេញការសិក្សានៅក្នុង និងក្រៅប្រទេសតាមតំរូវការរបស់នគរបាលជាតិ ។

៤- មន្ត្រីនគរបាលជាតិ ពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលមិនទាន់ផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្ត ។

៥- មន្ត្រីនគរបាលជាតិដែលអនុញ្ញាតច្បាប់ក្នុងធុរៈផ្ទាល់ រយៈពេលសំរាកព្យាបាលជម្ងឺ និងបាត់ខ្លួនក្នុងបេសកកម្ម ។

**មាត្រា ៥ :** ការបញ្ឈប់ផ្តល់ប្រាក់បៀវត្សរ៍ ត្រូវធ្វើទៅតាមថ្ងៃខែឆ្នាំដែលកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងករណីដូចខាងក្រោម :

១- មន្ត្រីនគរបាលជាតិដែលសុំលាឈប់ពីការងារដោយមានការអនុញ្ញាត ។

២- មន្ត្រីនគរបាលជាតិដែលមានប្រកាសបណ្តេញចេញពីក្របខ័ណ្ឌនគរបាលជាតិ ។

៣- មន្ត្រីនគរបាលជាតិដែលអវត្តមានគ្មានការអនុញ្ញាត ឬហួសពេលកំណត់ដោយសំអាងលើប្រធានសក្តិមិនសមស្រប ។

៤- មន្ត្រីនគរបាលជាតិ ពលី ពិការ មរណៈ និវត្តជន បាត់បង់សមត្ថភាពការងារដែលបានផ្ទេរទៅឱ្យក្រសួងទទួលបន្ទុកអតីតយុទ្ធជនគ្រប់គ្រងបន្តរួចហើយ ។

៥- មន្ត្រីនគរបាលជាតិដែលមានសាលក្រមរបស់តុលាការបញ្ជាក់ថាជាទណ្ឌិត ។

**មាត្រា ៦ :** ប្រាក់របបផ្សេងៗទៀត ក្រៅពីប្រាក់បៀវត្សរ៍មូលដ្ឋាន ត្រូវបន្តអនុវត្តជាធរមាន ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន-ពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

សូមចុះហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

***កន្លែងទទួល :***

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ៧

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ